# តុលាការ Nuremburg

តុលាការនេះ កើតឡើងចេញពីការសម្រេចចិត្តរបស់ក្រុមប្រទេសឈ្នះសង្គ្រាមលោកលើកទី២ ដែលមានសហរដ្ឋអាមេរិក និង បារាំងជាដើម។ មានការចរចារជាច្រើនដំណាក់កាល ក្នុងនោះមានការចរចារនៅទីក្រុងឡុងដ៍ (London negotiation) ហើយក្រោយមក កិច្ចប្រជុំបានអនុម័ត ធម្មនុញ្ញទីក្រុងឡុងដ៍ (London Charter) ដែលបង្កើតនូវលក្ខន្តិកៈតុលាការយោធាអន្តរជាតិ Nuremburg (Nuremburg International Military Tribunal Statute)។

តុលាការនេះ មានសមត្ថកិច្ចលើ បទឧក្រិដ្ឋកម្មសង្គ្រាម (war crime) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (crime against humanity)។ បទបញ្ជាថ្នាក់លើ (superior order) មិនមែនជាការដោះសាររួចខ្លួនទេ (excuse) តែអាចជាស្ថានសម្រាលទោស។

តុលាការ បានចោទមនុស្សចំនួន២៤នាក់ ក្នុងនោះ មានមេដឹកនាំកំពូលរបបអ៊ីត្លែរផងដែរ។ មានបញ្ហាផ្លូវច្បាប់ជាច្រើន ត្រូវបានលើកឡើង ដូចជា គោលការណ៍នីត្យានុកូលភាព (principle of legality) ពាក់ព័ន្ធបទល្មើសប្រឆាំងនឹងសន្តិភាព (crime against peace)។ ក្នុងន័យនេះ មានការអះអាងថា គោលការណ៍នីត្យានុកូល មិនមែនជាការកម្រិតលើអធិបតេយ្យភាពទេ (sovereignty) តែជាគោលការណ៍យុត្តិធម៌ (principle of justice) ហើយសន្ធិសញ្ញា Kellogg-Briand ឆ្នាំ១៩២៨ បានចែងអំពីបទល្មើសប្រឆាំងនឹងសន្តិភាព។

តុលាការនេះ បានបង្កើតជាដំបូងក្នុងប្រវត្តិសាស្ត្រនៃការទទួលខុសត្រូវបុគ្គលបំពានច្បាប់អន្តរជាតិ៖ *បទឧក្រិដ្ឋប្រឆាំងនឹងច្បាប់អន្តរជាតិ ត្រូវបានប្រព្រឹត្តដោយមនុស្ស មិនមែនអង្គភាពអរូបិយទេ ហើយមានតែតាមរយៈកាត់ទោសបុគ្គល ដែលប្រព្រឹត្តបទល្មើសនោះ ទើបបទប្បញ្ញត្តិច្បាប់អន្តរជាតិ ត្រូវបានអនុវត្ត...បុគ្គលមានកាតព្វកិច្ចអន្តរជាតិ ហួសពីកាតព្វកិច្ចក្រោមច្បាប់ជាតិ*។[1]

ទោះបីជាយ៉ាងនេះក្តី អ្នកសិក្សាខ្លះ បានរិះគន់ ថាតុលាការនេះ ជាប្រព័ន្ធយុត្តិធម៌នៃអ្នកឈ្នះ (victor's justice) ដោយសារ បទឧក្រិដ្ឋប្រព្រឹត្តដោយអ្នកឈ្នះ មិនត្រូវបានចោទប្រកាន់ទេ។ ទំនងទំនាក់ រវាងចៅក្រម និងរដ្ឋអាជ្ញាមានភាពជិតស្និទ្ធ ហើយមេធាវី មិនអាចទទួលបានឯកសារពេញលេញ

---

[1] Crimes against international law are committed by men, not abstract entities, and only by punishing individuals who committed such crimes can the provisions of international law be enforced...individuals have international duties which transcend the national obligations of obedience imposed by the individual state (Judgment of Nuremburg, 221).

ហើយភស្តុតាងជាប្រយោជន៍ដល់ជនត្រូវចោទ មិនត្រូវបានទទួលយកទាំងស្រុង (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 441-443)។